# ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ភ្នំពេញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ **************

លេខ:៤៣៤ / ២៦.៥.២០១១

សាលដីកា

## គាទនាមប្រជារាស្ត្រខ្មែរ

លេខ: ៨៣ ក្រ.III.ស/២៦.១០.២០១២

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៤ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ រវាង ៖

១. ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរអ៊ីស្លាម មុខរបរៈកម្មករអគ្គីសនី កំរិតវប្បធម៌ថ្នាក់ទី៧ ទីលំនៅកំណើតភូមិតាដឹប ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ទីលំនៅមុនចាប់ខ្លួន [redacted] ក្រុងកំពត ខេត្តកំពត ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ឃុំខ្លួនថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។

២. ជនជាប់ចោទឈ្មោះ [redacted] លាង ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរៈកម្មករអគ្គីសនី កំរិតវប្បធម៌ថ្នាក់ទី៧ កើតនៅភូមិក្រាំង ឃុំក្រាំងអំពិល ស្រុកកំពង់បាយ ខេត្តកំពត ទីលំនៅមុនចាប់ខ្លួន [redacted] ស្រុកទឹកឈូ ខេត្តកំពត ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ឃុំខ្លួនថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។

មេធាវីការពារជនជាប់ចោទទាំងពីរនាក់ លោកស្រី [redacted] ម៉េងអ៊ាម។ ៗ

ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

៣. ជនជាប់ចោទឈ្មោះ [redacted] សើ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម មុខរបរៈកម្មករ កំរិតវប្បធម៌ថ្នាក់ទី៦ កើតនៅភូមិតាដឹប ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត លំនៅមុនចាប់ខ្លួន [redacted] ងខ្មែរ [redacted] ក្រុងកំពត ខេត្តកំពត ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] នៅលើវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ឃុំខ្លួនថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។

មេធាវីការពារលោកស្រី [redacted] ម៉េងអ៊ាម។

ជាប់ចោទពីបទ: សមគំនិតក្នុងបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] លីនដា ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ [redacted] ក្រុងកំពត ខេត្តកំពត។

**ឯដំណើររឿងមានដូចតទៅ៖**

កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ វេលាម៉ោងប្រមាណ៧ និង៣០នាទីយប់ មានឈ្មោ[redacted] វ៉ាន់ឌី ឈ្មោះ[redacted] លាង និងឈ្មោ[redacted] សើ បានជិះម៉ូតូចំនួន២គ្រឿង ចូលច្រៀងខារ៉ាអូខេនៅហាងឈ្មោះ រាត្រីជួបភក្រ្ត័ ស្ថិតនៅភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពុត ខេត្តកំពត។ ពេលច្រៀងនោះឈ្មោះ [redacted] វ៉ាន់ឌី បានហៅនារីបំរើខារ៉ាអូខេឈ្មោះ [redacted] លីនដា មកអង្គុយជាមួយក្នុងបំណងនិយាយលួងលោម និងរំលោភសេពសន្ថវៈ, ក្នុងគោលបំណងនេះ ឈ្មោះ [redacted] វ៉ាន់ឌី បានប្រើល្បិចដោយប្រាប់ឲ្យឈ្មោះ [redacted] លីនដា ចូលក្នុងបន្ទប់ទឹក នៅក្នុងបន្ទប់ខារ៉ាអូខេនេះ ដើម្បីប្រាប់រឿងមួយ តែឈ្មោះ [redacted] លីនដា ពុំព្រមទៅ ស្រាប់តែឈ្មោះ [redacted] វ៉ាន់ឌី ចាប់អូសទាញដៃចូលក្នុងបន្ទប់ទឹកនោះរួចធ្វើសកម្មភាពរំលោភរហូតបានសម្រេច,បន្ទាប់មកឈ្មោ[redacted] លាង ដែលនៅឈរក្បែរទ្វារបន្ទប់ទឹក បានចូលទៅចាប់រំលោភលើឈ្មោះ[redacted] លីនដា បានសម្រេចទៀត ចំណែកឯឈ្មោះ [redacted] សើ ជាបក្សពួកនៅឈរក្បែរមាត់ទ្វារចាំយាមផ្លូវ, ក្នុងពេលនោះដែរ ដោយមានការសង្ស័យឈ្មោះ [redacted] ធីហ្សា ជាម្ចាស់ហាងបានស្ទុះចូលក្នុងបន្ទប់បានឃើញហេតុការណ៍នេះ និងបានប្តឹងសមត្ថកិច្ច។ កំលាំងសមត្ថកិច្ចក៏បានចាប់ឃាត់ខ្លួន ជនទាំងបីនាក់ខាងលើនៅយប់ដដែលនោះ រួចបានបញ្ជូនមកតុលាការឃុំខ្លួននៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៩ «ខ» ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោស:

ក. ឈ្មោះ [redacted] វ៉ាន់ឌី ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] លាង ភេទប្រុស អាយុ២៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ក្នុងម្នាក់ៗ ៧ឆ្នាំ (ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន។

ពីបទ: រំលោភសេពសន្ថវៈ

ខ. ឈ្មោះ [redacted] សើ ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារកំណត់៦ឆ្នាំ(ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន,

ពីបទ: សមគំនិតក្នុងបទរំលោភសេពសន្ថវៈ

ចំណុច (ក+ខ) ប្រព្រឹត្តនៅភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៩ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

២- ប្រគល់:

- ម៉ូតូ ម៉ាកហុងដា ធុនសេ១២៥ ស៊េរី២០០៥ ពណ៌ខ្មៅពាក់ស្លាកលេខ កំពត ០១៤៤ មួយគ្រឿង ឲ្យជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី ឬ ឪពុក-ម្តាយ ឬ អាណាព្យាបាល ជននេះវិញ។

- ម៉ូតូ ម៉ាកស្តេប ពណ៌ត្រួយចេក លាយខ្មៅ មួយគ្រឿង ឲ្យជនជាប់ចោទឈ្មោះ [redacted] សើ ឬ ឪពុក-ម្តាយ ឬ អាណាព្យាបាល ជននេះវិញ។ នៅពេលសាលក្រមនេះស្ថាពរតទៅ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ, ជនរងគ្រោះ, មេធាវីរបស់គូភាគី ទុកសិទ្ធិប្តឹងតវ៉ាតាមច្បាប់។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៣០ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] នឿន មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី, ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] សើ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ «ខ» ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

<u>**នាពេលសវនាការ**</u>

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី ឆ្លើយថា ខ្លួនអត់បានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនអត់សុខចិត្តទើបខ្លួនប្តឹងឧទ្ធរណ៍មក ខ្លួនពិតជាអត់បានប្រព្រឹត្តទេ។ ចម្លើយនៅសមត្ថកិច្ចប៉ូលីស ខ្លួនអត់បានឆ្លើយទេ ប៉ូលីសជាអ្នកសរសេរដោយខ្លួនឯង រួចចាប់ខ្លួនឲ្យផ្តិតមេដៃ ប៉ូលីសបានគំរាមសំឡុតខ្លួនឲ្យឆ្លើយ។ ខ្លួនអត់ស្គាល់ជនរងគ្រោះទេ ខ្លួនមិនដែលមានទំនាស់ជាមួយម្ចាស់ហាង និងជនរងគ្រោះទេ, ពេលនេះនារីរងគ្រោះនៅ ៣

ឯណាខ្លួនអត់ដឹងទ។ ខ្លួនសុំបដិសេធរាល់ចម្លើយនៅប៉ូលីស និងនៅសាលាដំបូង។ សំណូមពរ សុំលើកលែង ចោទប្រកាន់លើរូបខ្លួន។

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌីបានឆ្លើយនៅនគរបាល និងនៅសាលាដំបូង។

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ហាងបានឆ្លើយនៅនគរបាល និងនៅសាលាដំបូង។

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] សីបានឆ្លើយនៅនគរបាល និងនៅសាលាដំបូង។

ក្រឡាបញ្ជីអានចម្លើយ និងសំបុត្រ របស់ជនរងគ្រោះ បានឆ្លើយនៅសាលាដំបូងខេត្តកំពត។

ជនជាប់ចោទឈ្មោះ [redacted] លាង ឆ្លើយថា ចំពោះសកម្មភាពទាំងអស់នេះ ខ្លួនមិនបានប្រព្រឹត្តទេ ហើយពួកខ្លួនអត់បានដឹងរឿងអីទាំងអស់, ពាក់ព័ន្ធការចោទប្រកាន់លើរូបពួកខ្លួន ខាងសមត្ថកិច្ចគាត់មិនបាន ពិនិត្យកន្លែងហេតុច្បាស់លាស់ទេ ហើយក៏មិនបានធ្វើកោសលវិច័យលើនារីរងគ្រោះភ្លាមៗដែរ។ ខ្លួនទៅច្រៀង នៅកន្លែងកើតហេតុលើកទី១ ពេលខ្លួនច្រៀងខ្លួនបានអង្គុយច្រៀងជាមួយនារីរងគ្រោះនៅលើសាឡុង ខ្លួនមិន ទាន់បានឲ្យលុយផង ស្រាប់តែប៉ូលីសមកចាប់ខ្លួនតែម្តង, ខ្លួនសុំបដិសេធរាល់ចម្លើយនៅប៉ូលីស និងនៅ សាលាដំបូង។ ក្នុងរយៈពេលដែលខ្លួនជាប់ពន្ធនាគារ ខ្លួនមិនដឹងថា ជនរងគ្រោះធ្វើអ្វីទេ តែបើជនរងគ្រោះ ពិតជាមានផ្ទៃពោះមែន ខ្លួនសុំឲ្យពេទ្យពិនិត្យ បើឃើញថាកូននោះជាកូនរបស់ខ្លួន ខ្លួននឹងទទួលខុសត្រូវ។ សំណូមពរ សុំលើកលែង ចោទប្រកាន់លើរូបខ្លួន។

ជនជាប់ចោទឈ្មោះ [redacted] សី ឆ្លើយថា ខ្លួនអត់បានប្រព្រឹត្តទេ ខ្លួនទៅច្រៀងនៅកន្លែងកើតហេតុលើកទី១ ពេលខ្លួនច្រៀង ខ្លួនបានអង្គុយច្រៀងជាមួយនារីរងគ្រោះនៅលើសាឡុង ខ្លួនមិនទាន់បានឲ្យលុយផង ស្រាប់ តែប៉ូលីសមកចាប់ខ្លួនតែម្តង, ខ្លួនសុំបដិសេធរាល់ចម្លើយនៅប៉ូលីស និងនៅសាលាដំបូង។ សំណូមពរ សុំលើកលែង ចោទប្រកាន់លើរូបខ្លួន។

## <u>សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ</u>

ពាក់ព័ន្ធក្នុងរឿងនេះ ជនជាប់ចោទបានសារភាពនៅដំណាក់កាលនគរបាល តែនៅដំណាក់កាល ព្រះរាជអាជ្ញាគាត់បានបដិសេធថាមិនបានប្រព្រឹត្តទេ, មួយទៀតពាក់ព័ន្ធនឹងចម្លើយជនរងគ្រោះដែលឆ្លើយតាម លិខិតពេលសវនាការសាលាដំបូង គឺគាត់បានបដិសេធថា ជនជាប់ចោទមិនបានរំលោភខ្លួនទេ ឯចម្លើយនៅ សមត្ថកិច្ចនគរបាលខ្លួនថាត្រូវពួកគេចាប់រំលោភខ្លួននោះ ម្ចាស់ហាងជាអ្នកចាប់បង្ខំឲ្យខ្លួនឆ្លើយ, ចំពោះលិខិត បំភ្លឺនេះជាលិខិតដែលខ្លួនសរសេរដោយរូបខ្លួន មិនមាននរណាបង្ខំខ្លួនទេ, នៅថ្ងៃកើតហេតុខ្លួនបានចូលបន្ទប់ ទឹកហើយពេលម្ចាស់ហាងរុញទ្វារបន្ទប់ទឹកចូល ខ្លួនភ្ញាក់ក៏របូតខោតែម្តង, ១-ហេតុអីជនរងគ្រោះឆ្លើយជួយជន ជាប់ចោទ មួយទៀតជនរងគ្រោះថាម្ចាស់ហាងគំរាមបង្ខំឲ្យឆ្លើយ, នេះជាចំណុចគួរឲ្យសង្ស័យ ព្រោះគ្មានសាក្សី ណាបញ្ជាក់ច្បាស់ជាងជនរងគ្រោះផ្ទាល់ទេ។ ចំណុចមួយទៀត លិខិតជនរងគ្រោះជាអ្នកសរសេរដោយខ្លួនឯង ហើយបញ្ជាក់ថា ខ្លួនគ្មានបានផលប្រយោជន៍អ្វីពីជនជាប់ចោទទេ នេះជាចម្លើយដែលទាក់ទងទៅនឹងផ្លូវច្បាប់

មួយទៀតចាប់ពីពេលកើតហេតុមកខ្លួនមិនដែលមានទំនាក់ទំនងស្នេហាជាមួយនរណាឡើយ តែពេលនេះខ្លួនមានផ្ទៃពោះ។ ថ្ងៃកើតហេតុថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ បើនារីរងគ្រោះត្រូវបាន ជនជាប់ចោទទាំងបីនាក់រំលោភ ច្បាស់ជាមាននរណាម្នាក់ ក្នុងចំណោមជនល្មើសទាំងបីនាក់នេះជាឪពុក បើរាប់មកទល់ថ្ងៃសវនាការគឺបានរយៈពេលប្រាំខែ ហេតុអ្វីមិនមានវត្តមានជនរងគ្រោះចូលរួម។ បើគិតមក ទល់ពេលនេះ កូនកើតមកបានពីរឆ្នាំ(ខ្វះតិចតួច)។ តំណាងមហាអយ្យការសុំក្រុមប្រឹក្សាពិនិត្យពិចារណាលើចំណុចនេះថាតើគួរសម្រេចសេចក្តី ឬ គួរសម្រេចចាត់របៀប តាមរកជនរងគ្រោះ បើគាត់មានផ្ទៃពោះមែន បើកូននោះកើតមកហើយ ត្រូវធ្វើកោសល្យវិច័យមើល ហើយតើកម្រិតវប្បធម៌គាត់ដល់ណា។ ជនជាប់ចោទបានឆ្លើយបដិសេធនៅសាលាដំបូងមានតែចម្លើយនៅនគរបាលតែមួយគត់ដែលជនជាប់ចោទសារភាព ដូច្នេះ តំណាងមហាអយ្យការសូមឲ្យចាត់របៀបស៊ើបសួរលើចំណុចៈ ១. រកជនរងគ្រោះ បើគាត់មានផ្ទៃពោះមែន ពេលកូននោះកើតមកត្រូវធ្វើកោសល្យវិច័យបញ្ជាក់ តើជាកូនរបស់អ្នកណា, ២. លិខិតដែល គាត់សរសេរដោយដៃជារបស់គាត់ ឬ មិនមែនហើយតើកម្រិតវប្បធម៌គាត់ដល់ណា, សុំក្រុមប្រឹក្សាពិនិត្យ ពិចារណា និងសម្រេច។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

រឿងនេះជាបទឧក្រិដ្ឋ បើមើលពីការផ្តន្ទាទោសឃើញថាសមល្មម ហើយក្នុងសវនាការពេលនេះជនជាប់ចោទទាំងបីនាក់បានបដិសេធរាល់ចម្លើយរបស់គាត់ ហើយបើមើលតាមលិខិតរបស់ជនរងគ្រោះឃើញថាគាត់មិនបានទទួលការចាប់រំលោភទេ, ដើម្បីផ្តល់ភាពយុត្តិធម៌ដល់កូនក្តីខ្លួនទាំងបីនាក់ ខ្លួនសុំលោកប្រធានមេត្តាចាត់របៀបថា តើកូនដែលកើតមកនោះជាកូនរបស់អ្នកណា?តើការចាប់រំលោភលើផ្លូវភេទនេះកើតឡើង ឬ យ៉ាងណា?

ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍លេខ ៣០ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] នឿន មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី, ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] សើ ធ្វើនៅក្នុងកំណត់ច្បាប់តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ជនជាប់ចោទ បានឆ្លើយសារភាពនៅចំពោះមុខមន្ត្រីនគរបាលរៀងៗ ខ្លួនថា:

- ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី ថា នៅថ្ងៃកើតហេតុនោះ ខ្លួនបានហៅស្រីម្នាក់ឈ្មោះ លីនដា

ឲ្យមកច្រៀង ហើយបបួលនាងឲ្យចូលក្នុងបន្ទប់ទឹក រួចចាប់រំលោភតែម្តង។ ពេលខ្លួនរំលោភរួច [redacted] លាង ចូលម្តង ចាប់រំលោភបន្ត, ពេលនោះម្ចាស់ហាងមកទាន់ ឃើញ [redacted] លាង កំពុងអោប លីនដា ដែលមិនទាន់ស្លៀកពាក់ខោអាវ។

- ជនជាប់ចោទឈ្មោះ [redacted] លាង ថា ឈ្មោះ [redacted] វ៉ាន់ឌី យក លីនដា ចូលបន្ទប់ទឹក រំលងមួយ សន្ទុះ ឈ្មោះ [redacted] ស៊ើ លបមើលឃើញ វ៉ាន់ឌី និង លីនដា កំពុងរួមរក្ស, បន្ទាប់មកខ្លួនទៅលបមើលក៏ឃើញ វ៉ាន់ឌី កំពុងរួមរក្សជាមួយ លីនដា ដែរ, ក្រោយ វ៉ាន់ឌី រួមភេទហើយ ខ្លួនក៏ស្ទុះចូលទៅរួមភេទជាមួយនារីនោះដែរ។

- ជនជាប់ចោទឈ្មោះ [redacted] ស៊ើ ថា ពេលកំពុងច្រៀង [redacted] វ៉ាន់ឌី ហៅ លីនដា ចូលបន្ទប់ទឹក ហើយ ឈ្មោះ [redacted] លាង អ្នកយាមមាត់ទ្វារបន្ទប់ទឹក, វ៉ាន់ឌី ចូលបន្ទប់ទឹកបានប្រហែល៥នាទី ទើបចេញមកវិញ ហើយឲ្យខ្លួនចូល តែខ្លួនថា មិនហ៊ាន ភ្លាមនោះ [redacted] លាង ក៏ស្ទុះចូលទៅក្នុងបន្ទប់ទឹកបានប្រហែល១០នាទី, ពេលនោះខ្លួនឃើញ [redacted] លាង អោបថើប លីនដា រួចរំលោភ, ខ្លួនឃើញដោយមើលតាមប្រហោងទ្វារកន្លែងដាក់សោ។

ដូច្នេះ ការឆ្លើយបដិសេធរបស់ជនជាប់ចោទ គ្រាន់តែ ជាការដោះសារប៉ុណ្ណោះ ព្រោះថាៈ

៣. តាមចម្លើយសាក្សីឈ្មោះ [redacted] សូរិយាហៅ សាយ័ន្ត ថា នៅពេលនោះម៉ោងប្រហែល៨ជាង ខ្លួនឆ្ងល់ដោយក្នុងបន្ទប់នោះឮសូរតែបទញាក់ ពុំឃើញមនុស្សច្រៀង ខ្លួនទៅអើតមើលឃើញតែមនុស្សប្រុសម្នាក់ឈរខ្ទប់ទ្វារបន្ទប់ទឹក ឯប្រុស២នាក់ និង លីនដា មិនឃើញ ខ្លួនក៏ទៅប្រាប់ម្ចាស់ផ្ទះ ម្ចាស់ផ្ទះធាក់ទ្វារ រួចលូកដៃបើកឃើញ៣នាក់នៅក្នុងបន្ទប់ទឹក ពេលនោះម្នាក់ផាត់ចេញមកដោយរូតខោបណ្តើរ ឯ លីនដា ពុំមានស្លៀកខោទេ និងយំផង ចំណែកម្នាក់ស្ងួមចេញក្រោយគេ។

៤. តាមពាក្យបណ្តឹង និងចម្លើយនៅនគរបាល និងនៅចៅក្រមស៊ើបសួរ របស់នារីរងគ្រោះ មាស លីនដា ថា នៅថ្ងៃកើតហេតុឈ្មោះ [redacted] វ៉ាន់ឌី, [redacted] លាង និងម្នាក់ទៀតមិនស្គាល់ឈ្មោះ ហៅខ្លួនឲ្យចាក់ស្រាឲ្យបានប្រហែលកន្លះម៉ោង ម្នាក់ដែលខ្លួនមិនស្គាល់ បានទៅប្រាប់ម៉ាក់ខ្លួនឲ្យដូរបទញាក់។ ពេលកំពុងផឹកស៊ី និងច្រៀងបទកំពុងឮខ្លាំងឈ្មោះ [redacted] ន់ឌី ហៅខ្លួនឲ្យចូលបន្ទប់ទឹកប្រាប់រឿងមួយ ខ្លួនមិនព្រមចូល ភ្លាមនោះ វាចាប់ដៃខ្លួនអូសចូលបន្ទប់ទឹក ខ្លួនខំរើបំរាស់ និងស្រែក វាខ្ទប់មាត់ជាប់គំរាមមិនឲ្យរើ រួចចាប់រំលោភខ្លួនបានសម្រេច រួចវាចេញទៅក្រៅ ទើបឈ្មោះ [redacted] លាង ចូលទៅចាប់ខ្លួនរំលោភបន្តទៀត។

- តាមលិខិតបំភ្លឺ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ជនរងគ្រោះ [redacted] លីនដា ថា ជនទាំង៣នាក់នេះ មិនបានរំលោភខ្លួនទេ តែនៅចុងលិខិតឈ្មោះនេះបានបញ្ជាក់ថា តាំងពីថ្ងៃកើតហេតុមកដល់ពេលនេះ ខ្លួនពុំមានទំនាក់ទំនងស្នេហាជាមួយអ្នកណាទៀតទេ ឥឡូវនេះខ្លួនកំពុងមានផ្ទៃពោះ។

៥. ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទនៅសមត្ថកិច្ចនគរបាល, ពាក្យបណ្តឹង និងចម្លើយនៅនគរបាល និងនៅចៅក្រមស៊ើបសួរ និងសេចក្តីបញ្ជាក់នៅចុងលិខិតបំភ្លឺ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ របស់ ន

ជនរងគ្រោ[redacted]លីនដា អាចកំណត់បានថា នៅថ្ងៃកើតហេតុ ពិតជាមានសកម្មភាពចាប់រំលោភសេពសន្ថវៈ ទៅលើជនរងគ្រោះ ប្រព្រឹត្តដោយជនជាប់ចោទ ប្រាកដមែន។

៦. មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី និងឈ្មោះ[redacted]លាង ពីបទ រំលោភសេពសន្ថវៈ និងលើជនជាប់ចោទឈ្មោះ [redacted] សើ ពីបទ សមគំនិតក្នុងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ខែតុលា ឆ្នាំ២០១០ បទល្មើសមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២៩ និងមាត្រា ២៤០ (៥) នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះគួរកែអត្ថបទច្បាប់ឲ្យបានត្រឹមត្រូវឡើងវិញ។

៧.សាលក្រមព្រហ្មទណ្ឌលេខ ០៩ «ខ» ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត សម្រេចមានលក្ខណៈសមស្រប គួរតម្កល់ទុកជាបានការ លើកលែងតែអត្ថបទច្បាប់ គួរកែប្រែដូចយល់ឃើញខាងលើ ក្រៅពីនេះ គួរតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣០ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ របស់ឈ្មោះ សៅ នឿន មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឌី, ឈ្មោះ [redacted] លាង និងឈ្មោះ[redacted] សើ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩ «ខ» ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ទុកជាបានការ លើកលែងតែអត្ថបទច្បាប់ ត្រូវកែពីមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌទៅជាមាត្រា ២៤០ ចំណុច៥ នៃក្រមព្រហ្មទណ្ឌ វិញ, ក្រៅពីនេះទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ

បើកផ្លូវសាទុក្ខតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា:[redacted] | ហត្ថលេខា[redacted] | ហត្ថលេខា[redacted] |

..........................................................................................

| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី ០៤ ខែ ៦ ឆ្នាំ ២០១៤ |
| | ក្រឡាបញ្ជី |